ព្រះ
ត្រៃបិដកបាលី
និង
សេចក្តីប្រៀបភាសាខ្មែរ
ទសយមិដក
ចុល្លវគ្គ បឋមភាគ
៥

កម្មក្ខន្ធក: បារិវាសិកក្ខន្ធក:

និងសមុច្ចយក្ខន្ធក:

ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុកន្ធាមហាសង្ឆរាជាធិបតី ហ្ស ក្រ
សម្តេចព្រះមហាសង្ឆរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

ព. ស. ២៥៥៣

Vinayapiṭaka

Cullavagga Paṭhamabhāga

9

kammakkhandhaka Pārivāsikakkhandhaka

&

Samuccayakkhandhaka

និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំក្រោយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឆបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យាកាពតរៀងទៅ ។

វត្តបឋុមធ. ថ្ងៃ៨ ០៨ ខែមិថុនា ឆ្នាំ ២០០៩

ហ្ស-ត្រ្ងី

Printed and donated for free distribution by
The Corporate Body of the Buddha Educational Foundation
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
This book is strictly for free distribution, it is not for sale.
សំរាប់ចាកចូនទានតែប៉ុណ្ណោះ

សេចក្តីណែនាំក្នុងការអាន

១- ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២- ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឆរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣- ចំពោះ **សន្ធឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

វិនយបិដក ចុល្លវគ្គ

បឋមភាគ

៩

កម្មក្ខន្ធកៈ ចារិកាសិកក្ខន្ធកៈ

និង

សមុច្ចយក្ខន្ធកៈ

វិនយបិដកេ

ចុល្លវគ្គស្ស បឋមោ ភាគো

នមោ តស្ស ភគវតោ អរហតោ

សម្មាសម្ពុទ្ធស្ស ។

កម្មក្ខន្ធកំ

[១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតি ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន បណ្ឌុកលោហិតកា ភិក្ខូ អត្តនា
ភណ្ឌនការកា កលហការកា វិវាទការកា ភស្ស-
ការកា សង្ឆេ អធិករណការកា យេបি ចញ្ញេ
ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា
ភស្សការកា សង្ឆេ អធិករណការកា តេ ឧប-
សង្កមិត្វា ឯវំ វទេន្តি មា ខោ តុម្ហេ អាយស្មន្តោ ឯសោ
អជេសি ពលវា ពលវំ បជិមន្តេថ តុម្ហេ តេន បណ្ឌិតតា
ច ព្យត្តតា ច ពហុស្សុតតា ច អលមត្តតា ច មា

វិនយបិដក

ចុល្លវគ្គ បឋមភាគ

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ

ជាព្រះអរហន្តសម្ពុទ្ធអង្គនោះ ។

កម្មក្ខន្ធក:

[១] *សម័យនោះ ព្រះសព្វញ្ញុពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ[១] ទាំងឡាយ ជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឆដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃទៀត ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឆដូចគ្នាដែរ ហើយនិយាយពាក្យយ៉ាងនេះថា លោកមានអាយុទាំងឡាយ មិនត្រូវឱ្យភិក្ខុនុ៎ះផ្ទាលផ្ទាញ់ពួកលោកបានទេ ចូរលោកវាល់គ្នាប្រឹងជជែកឱ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាច*

---

១ ភិក្ខុពីរូបនេះ នៅក្នុងពួកឆព្វគ្គិយភិក្ខុ ក្នុងអដ្ឋកថា ថា សូម្បីតែសិស្សគណរបស់ភិក្ខុពីរូបនោះ ក៏គេហៅថា បណ្ឌុក:និងលោហិតក:ដែរ ។

ចស្ស ភាយិត្ត មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ កណ្ហានានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច កណ្ហានានិ កិយ្យោការាយ វេបុល្លាយ សំវត្តន្តិ ។ យេ តេ ភិក្ខូ អប្ប៎ិច្ឆា សន្តុដ្ឋា លជ្ជិនោ កុក្កុចិ្ចកា សិក្ខា-កាមា តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម បណ្ឌុកលោហិតកា ភិក្ខូ អត្តនា កណ្ហានការកា កលហការកា វិវាទការកា កស្សការកា សង្ឆ្យ អធិការណការកា យេបិ ចញ្ញេ ភិក្ខូ កណ្ហានការកា កលហការកា វិវាទការកា កស្សការកា សង្ឆ្យ អធិការណការកា តេ ឧបសង្កមិត្វា ឝ្ឝ ១ក្ខន្តិ មា ១ោ តុម្ហេ អាយស្ម១ន្តោ ឝ១ សោ អ១េ១ សិ ១ លវ ១ ១ លវ ១ បដិ១ ១ ១

ជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្ជាចភិក្ខុនោះឱ្យសោះ ព្រោះយើងរាល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះ ការបង្ក្រហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្ក្រហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្តីអៀនខ្មាស មានសេចក្តីរអែង ជាអ្នកប្រាថ្នាក្នុងសិក្ខា ភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀលបន្ទុះបង្ហាប់ថា ហេតុអ្វី បានជាពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុ ជាអ្នកបង្ក្រហេតុ បង្ក្រជម្លោះ បង្ក្រវិវាទ បង្ក្រតិរច្ឆានកថា បង្ក្រអធិករណ៍ ក្នុងសង្ឆដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃទៀត ដែលជាអ្នកបង្ក្រហេតុ បង្ក្រជម្លោះ បង្ក្រវិវាទ បង្ក្រតិរច្ឆានកថា បង្ក្រអធិករណ៍ក្នុងសង្ឆដូចគ្នាដែរ ហើយនិយាយពាក្យយ៉ាងនេះថា លោកមានអាយុទាំងឡាយ មិនត្រូវឱ្យភិក្ខុនុ៎ះ ផ្ទាលផ្ទាញ់ពួកលោកបានទេ ចូរលោករាល់គ្នាប្រឹងជជែកឱ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្ជាចភិក្ខុនោះឱ្យសោះ ព្រោះយើងរាល់គ្នា ក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះ ការបង្ក្រហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្ក្រហេតុទាំងឡាយ ដែលកើតឡើងហើយ

កិយ្យាការាយ វេបុល្លាយ សំវត្តន្តីតិ ។ អថខោ តេ
ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

[២] អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ ប-
ការណេ ភិក្ខុសង្ឆំ សន្និចាតាបេត្វា ភិក្ខូ បដិបុច្ឆិ
សចំ កិរ ភិក្ខវេ បណ្ណកលោហិតកា ភិក្ខូ អត្តនា
ភណ្ឌនការកា កលហការកា វិវាទការកា ភស្ស-
ការកា សង្ឆ អធិការណការកា យេបិ ចញ្ញេ ភិក្ខូ
ភណ្ឌនការកា កលហការកា វិវាទការកា ភស្ស-
ការកា សង្ឆ អធិការណការកា តេ ឧបសន្តមិត្វា
ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ
ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច
ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា ច មា
ចស្ស ភាយិត្ត មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។
តេន អនុប្ឋន្ធានិ ចេវ ភណ្ឌនានិ ឧប្ឋជ្ជន្តិ ឧប្ឋន្ធ-
និ ច ភណ្ឌនានិ កិយ្យាការាយ វេបុល្លាយ សំវត្ត-
ន្តីតិ ។ សចំ ភគវាតិ[១] ។ វិគ្រហិ ពុទ្ធោ ភគវា

១ ឱរោបិយមរម្ម្ហបោត្ថកេសុ ឥតិសទ្ទោ ន បញ្ញាយតិ ។

ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ លំដាប់នោះ ភិក្ខុអម្ចាលនោះ ក៏យកសេចក្ដីនុ៎ះ ក្រាបបង្គំទូលព្រះមានព្រះភាគ ។

[២] ព្រោះនិទានេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ឱ្យប្រជុំភិក្ខុសង្ឆ ហើយសួរចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុ ដែលជាអ្នកបង្ក្រហេតុ បង្ក្រជម្ងោ: បង្ក្រវិវាទ បង្ក្រតិរច្ឆានកថា បង្ក្រអធិករណ៍ក្នុងសង្ឆ ដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃ ដែលជាអ្នកបង្ក្រហេតុ បង្ក្រជម្ងោ: បង្ក្រវិវាទ បង្ក្រតិរច្ឆានកថា បង្ក្រអធិករណ៍ក្នុងសង្ឆដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកមានអាយុទាំងឡាយ មិនត្រូវឱ្យភិក្ខុនុ៎ះ ផ្ទាលផ្ទាញ់ពួកលោកបានទេ ចូរលោកវាល់គ្នាប្រឹងជជែកឱ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោក ចូរកុំខ្ជាចភិក្ខុនោះឱ្យសោះ ព្រោះពួកយើងវាល់គ្នា ក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះ ការបង្ក្រហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្ក្រហេតុទាំងឡាយដែលកើតហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះសព្វញ្ញុពុទ្ធមានព្រះភាគទ្រង់តិះដៀលថា

អនុច្ឆវិកំ[1] ភិក្ខវេ តេសំ មោឃបុរិសានំ អនុលោ-
មិកំ អប្ផដិរូបំ អស្ឆាមណកំ អកប្ប្យំ អការណី-
យំ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា អត្តនា
ភណ្ឌនការកា ។ បេ ។ សង្ឆេ អធិករណការកា
យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា ។ បេ ។ សង្ឆេ
អធិករណការកា តេ ឧបសន្តមិត្វា ឯវំ វក្ខន្តិ មា ខោ
តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិ-
មន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុ-
ស្សុតតរា ច អលមត្តតរា ច មា ចស្ស ភាយិត្ថ មយំបិ
តុម្ហាកំ បក្ខា ភវិស្ឆាមាតិ ។ តេន អនុប្ឆ្ជានិ ចេវ
ភណ្ឌានិ ឧប្ឆ្ជន្តិ ឧប្ឆ្ជានិ ច ភណ្ឌានិ កិយ្យា-
ការាយ វេបុល្លាយ សំវត្តន្តិ នេតំ ភិក្ខវេ អប្ឆ្ជសន្ថានំ
ឯ បសាទាយ បសន្ថានំ ឯ កិយ្យាការាយ អថខ្ជេតំ[2]
ភិក្ខវេ អប្ឆ្ជសន្ថានំ ចេវ អប្ឆ្ជសាទាយ បសន្ថានំ ច
ឯកច្ចានំ អញ្ញថត្តាយាតិ ។

---

១ ឱ.ម. អនុច្ឆវិយំ ។ ២ ឱ.ម. អថខោ តំ ។

ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងអម្បាលនោះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុអ្វីបានជាមោឃបុរសទាំងអម្បាលនោះ បង្ក្រហេតុ ។ បេ ។ បង្ក្រអធិករណ៍ក្នុងសង្ឆដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្ក្រហេតុ ។ បេ ។ ជាអ្នកបង្ក្រអធិករណ៍ ក្នុងសង្ឆដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកមានអាយុទាំងឡាយ មិនត្រូវឱ្យភិក្ខុនុ៎ះ ផ្ទាលផ្ទាញ់ពួកលោកបានទេ ចូរលោកវាល់គ្នាប្រឹងជជែកឱ្យអស់ទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោក ចូរកុំខ្វាចភិក្ខុនោះឱ្យសោះ ព្រោះយើងវាល់គ្នា ក៏ជាបក្ខពួករបស់លោកទាំង-ឡាយដែរ ។ ព្រោះហេតុនោះ ការបង្ក្រហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើង ការបង្ក្រហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឱ្យកើតសេចក្ដីជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬដឹកនាំពួកជនដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមានតែដឹកនាំសេចក្ដីមិនជ្រះថ្លា ឱ្យកើតដល់ពួកជនដែលមិនទាន់ជ្រះថ្លានៅឡើយ និងដឹកនាំពួកជនខ្លះដែលជ្រះថ្លាស្រាប់ហើយ ឱ្យទាស់ចិត្តទៅវិញទេតើ ។

កម្មក្ខន្ធកេ តជ្ជនីយកម្មបណ្ឌុកលោហិតកវិគ្គហោ

[៣] អថខោ ភគវា បណ្ឌុកលោហិតកេ[១] ភិក្ខូ អនេកបរិយាយេន វិគ្គហិត្វា ឧព្ភតាយ ឧប្ផាសតាយ មហិច្ឆតាយ អសន្តុដ្ឋតាយ[២] សង្គណិការាយ គោ-សជ្ជសុ អវណ្ណំ ភាសិត្វា អនេកបរិយាយេន សុភរតា-យ សុវចសតាយ អប្ប៊ិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធូតស្ស ចាសាធិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណំ ភាសិត្វា ភិក្ខូ តេនេតទវោចុំ ។ ១ ។ ២ ។ ៣ ។ ៤ ។ ១ ។ ២ ។ ៣ ។ ៤ ។ ១ ។ ២ ។ ៣ ។ ៤

កម្មក្ខន្ធក: ការទ្រង់បន្ទោសនិងទ្រង់ឱ្យធ្វើតជ្ជនីយកម្ម ដល់បណ្ដុកភិក្ខុនិងលោហិតកភិក្ខុ

[៣] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់តិះដៀលពួកបណ្ដុកភិក្ខុ និងលោហិតកភិក្ខុដោយអនេកបរិយាយ ហើយទ្រង់សម្ដែងនូវទោសនៃ សភាពជាបុគ្គលដែលគេចិញ្ចឹមបានដោយកម្រ និងថែទាំបានដោយកម្រ ជាអ្នកមានសេចក្ដីប្រាថ្នាច្រើន មិនមានសេចក្ដីសន្ដោស នៅច្រឡូកច្រឡំ ដោយពួក មានសេចក្ដីខ្ជិលច្រអូស ទើបទ្រង់សម្ដែងគុណនៃសភាព ជាបុគ្គលដែលគេចិញ្ចឹមបានដោយងាយ និងថែទាំបានដោយងាយ ជាអ្នក មានសេចក្ដីប្រាថ្នាតិច មានសេចក្ដីសន្ដោស មានចិត្តផ្ងរផង់ កំចាត់បង់នូវ កិសេស នាំឱ្យកើតសេចក្ដីជ្រះថ្លា មិនសន្សំកិលេសវដ្ដ ប្រារព្ធសេចក្ដីព្យា-យាមដោយអនេកបរិយាយ ហើយទ្រង់សម្ដែងធម្មីកថាដ៏ល្មមសមគួរដល់ កម្មនោះ ។ ដល់ពួកភិក្ខុ រួចទ្រង់ត្រាស់ហៅពួកភិក្ខុមក ទើបមានព្រះពុទ្ធដី-កាថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឆចូរធ្វើតជ្ជនីយកម្ម[1]ដល់ បណ្ដុកភិក្ខុនិងលោហិតភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯតជ្ជនីយកម្មនោះ សង្ឆគប្បីធ្វើយ៉ាងនេះ ។ សង្ឆត្រូវចោទបណ្ដុកភិក្ខុនិងលោហិតកភិក្ខុជា មុន លុះចោទហើយគប្បីរំលឹក លុះរំលឹកហើយគប្បីលើកអាបត្តិឡើង លុះលើកអាបត្តិហើយ ភិក្ខុអ្នកឈ្វាសប្រតិពល គប្បីប្រកាសសង្ឆ ឱ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្ដាប់ខ្ញុំ ពួកបណ្ដុកភិក្ខុ*

---

1 កម្មដែលសង្ឆត្រូវធ្វើដល់ភិក្ខុដែលគួរគម្រាម ។

ឥមេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា កណ្ឌនការ-
កា កលហការកា វិវាទការកា កស្សការកា
សង្ឆ្យ អធិការណការកា យេបិ ចញ្ញេ ភិក្ខូ កណ្ឌន-
ការកា កលហការកា វិវាទការកា កស្សការ-
កា សង្ឆ្យ អធិការណការកា តេ ឧបសន្តមិត្វា ឯវំ
វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជ្ជេសិ
ពលវា ពលវំ បជិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច
ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា ច មា
ចស្ស ភាយិត្ត មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។
តេន អនុប្ឋន្ធានិ ចេវ កណ្ឌានិ ឧប្ឋជ្ជន្តិ ឧប្ឋន្ធានិ
ច កណ្ឌានិ កិយ្យោការាយ ឧបុណ្ណាយ សំវត្តន្តិ ។
យតិ សង្ឆ្យ បត្តកល្ល សង្ឆ្យ បណ្ឌុកលោហិ-
តកានំ ភិក្ខូនំ ឥជ្ជនីយកម្ម ករេយ្យ ។ ឯសា ញត្តិ ។
សុណាតុ មេ ភន្តេ សង្ឆ្យ ឥមេ បណ្ឌុកលោហិត-
កា ភិក្ខូ អត្តនា កណ្ឌនការកា ។ បេ ។ សង្ឆ្យ
អធិការណការកា យេបិ ចញ្ញេ ភិក្ខូ កណ្ឌន-
ការកា ។ បេ ។ សង្ឆ្យ អធិការណការកា តេ
ឧបសន្តមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ

និងលោហិតកភិក្ខុនេះ ជាអ្នកបង្ក្រហេតុ បង្ក្រជម្លោះ បង្ក្រវិវាទ បង្ក្រតិរច្ឆ-
នកថា បង្ក្រអធិករណ៍ក្នុងសង្ឆដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃ
ទៀត ដែលជាអ្នកបង្ក្រហេតុ បង្ក្រជម្លោះ បង្ក្រវិវាទ បង្ក្រតិរច្ឆានកថា បង្ក្រអ-
ធិករណ៍ ក្នុងសង្ឆដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកមានអាយុ
ទាំងឡាយ មិនត្រូវឱ្យភិក្ខុនុ៎ះផ្ទាលផ្ទាញ់ពួកលោកបានទេ ចូរលោកវាល់គ្នា
ប្រឹងជជែកឱ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នក
វាងវៃ ជាពហុស្សូត ទាំងជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួក
លោកចូរកុំខ្វាចភិក្ខុនោះឱ្យសោះ ព្រោះយើងវាល់គ្នា ក៏ជាពួករបស់លោក
ទាំងឡាយដែរ ។ ព្រោះហេតុនោះ ការបង្ក្រហេតុទាំងឡាយដែលមិនទាន់
កើតឡើង ក៏កើតឡើង ការបង្ក្រហេតុទាំងឡាយដែលកើតឡើងហើយ
ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ បើកម្មមានកាលគួរដល់សង្ឆ
ហើយ សង្ឆគប្បីធ្វើតជ្ជនីយកម្ម ដល់ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុចុះ ។
នេះជាញត្តិ ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្ដាប់ខ្ញុំ ពួកបណ្ដុ-
កភិក្ខុនិងលោហិតកភិក្ខុនេះ ជាអ្នកបង្ក្រហេតុ ។ បេ ។ បង្ក្រអធិករណ៍ក្នុង
សង្ឆដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្ក្រហេតុ
។ បេ ។ បង្ក្រអធិករណ៍ក្នុងសង្ឆដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា
លោកមានអាយុទាំងឡាយ មិនត្រូវឱ្យភិក្ខុនុ៎ះ ផ្ទាលផ្ទាញ់ពួកលោកបានទេ

កម្មក្ខន្ធកេ បណ្ដុកលោហិតកានំ តជ្ជនីយកម្មំ

ឯសោ អជេសិ ពលវា ពលវំ បជិមន្តេថ តុម្ហេ តេន
បណ្ឌិតតា ច ញ្ញត្តតា ច ពហុស្សុតតា ច អល-
មត្តតា ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា
ភវិស្សាមាតិ ។ តេន អនុប្ញ្ញានិ ចេវ ភណ្ឌានិ
ឧប្ញ្ញជ្ជន្តិ ឧប្ញ្ញានិ ច ភណ្ឌានិ ភិយ្យោភាវាយ
វេបុល្លាយ សំវត្តន្តិ ។ សង្ឆោ បណ្ដុកលោហិតកា-
ន៎ ភិក្ខូ តជ្ជនីយកម្មំ ករោតិ ។ យស្ស្ចាយស្ម-
តោ ខមតិ បណ្ដុកលោហិតកានំ ភិក្ខូ តជ្ជនីយ-
កម្មស្ស ការណំ សោ តុណ្ហីស្ស យស្ស ន ខ្ខមតិ
សោ ភាសេយ្យ ។ ទុតិយម្ប្ចិ ឯតមត្ថំ វទ្ធាមិ ។ សុ-
ណាតុ មេ ភន្តេ សង្ឆោ ឥមេ បណ្ដុកលោហិតកា
ភិក្ខូ អត្ត្ជា ភណ្ឌនការកា ។ បេ ។ សង្ឆេ អធि-
ករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា
។ បេ ។ សង្ឆេ អធិករណការកា តេ ឧបសង្ក-
មិត្ថា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្ម្ចន្តោ ឯសោ
អជេសិ ពលវា ពលវំ បជិមន្តេថ តុម្ហេ តេន បណ្ឌិ-
តតា ច ញ្ញត្តតា ច ពហុស្សុតតា ច អលមត្តតា

ចូរលោកវាល់គ្នាប្រឹងជជែក ឱ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ទាំងជាអ្នកអង់អាចជាងភិក្ខុនោះផង ម្យ៉ាងទៀត ពួកលោកចូរកុំខ្វាចភិក្ខុនោះឱ្យសោះ ព្រោះយើងវាល់គ្នាក៏ជាពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះ ការបង្ក្គហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្ក្គហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ សង្ឆធ្វើតជ្ជនីយកម្មដល់ពួកបណ្ដុកភិក្ខុនិងលោហតិកភិក្ខុ ។ ការធ្វើតជ្ជនីយ-កម្មដល់ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុ គួរដល់លោកមានអាយុអង្ក្គណា លោកមានអាយុអង្ក្គនោះត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្ក្គណា លោកមានអាយុអង្ក្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្ដីនេះ ជាគម្រប់ពីរដងផង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្ដាប់ខ្ញុំ ពួកបណ្ដុ-កភិក្ខុនិងលោហិតកភិក្ខុនេះជាអ្នកបង្ក្គហេតុ ។ លេ ។ បង្ក្គអធិករណ៍ ក្នុងសង្ឆ ដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្ក្គហេតុ ។ លេ ។ បង្ក្គអធិករណ៍ក្នុងសង្ឆដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកមានអាយុទាំងឡាយ មិនត្រូវឱ្យភិក្ខុនុ៎ះ ផ្ទាលផ្ទាញ់ពួកលោកបានទេ ចូរលោកវាល់គ្នាប្រឹងជជែកឱ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត និងជាអ្នកអង់អាចជាងភិក្ខុនោះ

ច មា ចស្ស ភាយិត្ត មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្ប‌ន្នានិ ចេវ ភណ្ឌានានិ ឧប្ប‌ជ្ជន្តិ ឧប្ប‌ន្នានិ ច ភណ្ឌានានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ សង្ឆ្យោ បណ្ឌុកលោហិតកានំ ភិក្ខូនំ ឥជ្ជនីយកម្មំ ករោតិ ។ យស្ស‌ាយស្ម‌ោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ ឥជ្ជនីយកម្ម‌ស្ស ការណំ សោ តុណ្ហ‌ស្ស យស្ស ន‌ក្ខ-មតិ សោ ភ‌ាសេយ្ យ ។ ត‌តិយ‌ម្ប‌ិ ឯ‌ត‌ម‌ត្ថ‌ំ ‌វ‌ទ‌ាម‌ិ ។ ‌ស‌ុ‌ណ‌ាតុ ‌ម‌ ‌ភ‌ន្ត‌ ‌ស‌ង្ឆ‌ោ ‌ឥ‌ម‌ ‌ប‌ណ្ឌ‌ុ‌ក‌លោ‌ហ‌ិ‌ត‌ក‌ា ‌ភ‌ិ‌ក្ខ‌ូ ‌អ‌ត្ត‌ជ‌ា ‌ភ‌ណ្ឌ‌ន‌ការ‌ក‌ា ។ ‌ប‌ ។ ‌ស‌ង្ឆ‌ោ ‌អ‌ធ‌ិ‌ក‌ារ-‌ណ‌ការ‌ក‌ា ‌យ‌ទ‌ិ ‌ច‌ញ្ញ‌ ‌ភ‌ិ‌ក្ខ‌ូ ‌ភ‌ណ្ឌ‌ន‌ការ‌ក‌ា ។ ‌ប‌ ។ ‌ស‌ង្ឆ‌ោ ‌អ‌ធ‌ិ‌ក‌ារ‌ណ‌ការ‌ក‌ា ‌ត‌ ‌ឧ‌ប‌ស‌ង្ក‌ម‌ិ‌ត្វ‌ា ‌ឯ‌ ‌ ‌

ម្យ៉ាងទៀត ពួកលោកចូរកុំខ្ជាចភិក្ខុនោះឱ្យសោះ ព្រោះយើងរាល់គ្នា ក៏ជាពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះ ការបង្ក្រហេតុទាំង-ឡាយដែលមិនទាន់កើត ក៏កើតឡើង ការបង្ក្រហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ សង្ឆ ធ្វើតជ្ជនីយ-កម្មដល់ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុ ។ ការធ្វើតជ្ជនីយកម្មដល់ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុនោះ ត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្ដីនេះជាគម្រប់បីដងផង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្ដាប់ខ្ញុំ ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុនេះ ជាអ្នកបង្ក្រហេតុ ។ បេ ។ បង្ក្រអធិករណ៍ក្នុងសង្ឆដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្ក្រហេតុ ។ បេ ។ បង្ក្រអធិករណ៍ក្នុងសង្ឆដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកមានអាយុទាំងឡាយ មិនត្រូវឱ្យភិក្ខុនុ៎ះ ផ្ទាលផ្ទាញ់ពួកលោកបានទេ ចូរលោករាល់គ្នាប្រឹងជជែកឱ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្ជាចភិក្ខុនោះឱ្យសោះ

មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ កណ្ហានានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច កណ្ហានានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ សង្ឆោ បណ្ឌ-កលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករោតិ ។ យស្ស្ចាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស ការណំ សោ តុណ្ហស្ស យស្ស ជក្ខមតិ សោ ភាសេយ្យ ។ ករតំ សង្ឆេន បណ្ឌុក-លោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ខមតិ សង្ឆស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៤] ឥមិ ភិក្ខវេ អដ្ឋេហិ សមន្នាគតំ តជ្ជនីយ-កម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុប-សន្តញ្ច អសម្មុខា ករតំ ហោតិ អប្បដិបុច្ឆា ករតំ ហោតិ អប្បដិញ្ញាយ ករតំ ហោតិ ឥមេហិ ខោ ភិក្ខវេ ឥមិ ហដ្ឋេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច ។

ព្រោះយើងរាល់គ្នា ក៏ជាពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះការបង្ក្គហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើង ការបង្ក្គហេតុទាំងឡាយ ដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ សង្ឆ្យធ្វើតជ្ជនីយកម្ម ដល់ពួកបណ្ណ្ដកភិក្ខុនិងលោហិតកភិក្ខុ ។ ការធ្វើតជ្ជនីយកម្ម ដល់ពួកបណ្ណ្ដកភិក្ខុនិងលោហិតកភិក្ខុ គួរដល់លោកមានអាយុអង្ក្គណា លោកមានអាយុអង្ក្គនោះត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្ក្គណា លោកមានអាយុអង្ក្គនោះ ត្រូវនិយាយឡើង ។ សង្ឆ្យបានធ្វើតជ្ជនីយកម្ម ដល់ពួកបណ្ណ្ដកភិក្ខុនិងលោហិតកភិក្ខុហើយ (ការធ្វើតជ្ជនីយកម្ម ដល់ពួកបណ្ណ្ដកភិក្ខុនិងលោហិតភិក្ខុនេះ) គួរដល់សង្ឆ្យ ព្រោះហេតុនោះ ទើបសង្ឆ្យស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

[៤] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលសង្ឆ្យរម្ងាប់ដោយអា-ក្រក់ផង ប្រកបដោយអង្ក្គ ៣ គឺកម្មដែលសង្ឆ្យធ្វើកំបាំងមុខ ១ កម្មដែលសង្ឆ្យធ្វើដោយការមិនសាកសួរ ១ កម្មដែលសង្ឆ្យធ្វើដោយមិនតាមពាក្យប្ដេជ្ញារបស់ភិក្ខុ ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្ម (កម្មមិនប្រកបដោយធម៌) ផង ជាអវិនយកម្ម (កម្មមិនប្រកបដោយវិន័យ) ផង ជាកម្មដែលសង្ឆ្យរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្ក្គ ៣ នេះឯង ។

[៥] អបរេហិបិ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច អនាបត្តិយា កតំ ហោតិ អនេសនាតា-មិនិយា អាបត្តិយា កតំ ហោតិ ឧសិតាយ អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហាន្តេហិ សមន្នា-គតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយ-កម្មញ្ច ទុរុបសន្តញ្ច ។

[៦] អបរេហិបិ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច អចោទេត្វា កតំ ហោតិ អសារេត្វា កតំ ហោតិ អាបត្តឺ អនាវេបេត្វា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្ម-កម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច ។

[៥] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយ-
កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត
គឺកម្មដែលធ្វើដោយមិនមានអាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិមិនមែន
ជាទេសនាគាមិនី[១] ១ កម្មដែលធ្វើដោយទេសិតាបត្តិ (អាបត្តិដែលភិក្ខុ
សម្តែងហើយ) ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជា
អវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣
នេះឯង ។

[៦] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយ-
កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត
គឺកម្មដែលមិនទាន់ចោទសិនហើយស្រាប់តែធ្វើ ១ កម្មដែលមិនទាន់រំលឹក
សិនហើយស្រាប់តែធ្វើ ១ កម្មដែលមិនទាន់លើកអាបត្តិឡើងហើយស្រាប់
តែធ្វើ ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្ម
ផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

---

១ អាបត្តិដែលសម្តែងមិនដាច់ អដ្ឋកថា ថា បានដល់អាបត្តិពីរកង គឺបារាជិក ១ សង្ឆា-
ទិសេស ១ តែសារត្ថទីបនីដីកា ថា អាបត្តិដែលមិនមែនជាទេសនាគាមិនីក្នុងទីនេះសំដៅយក
អាបត្តិបារាជិកតែម្យ៉ាង ព្រោះតជ្ជនីយកម្មសង្ឆធ្វើដល់ភិក្ខុដែលត្រូវអាបត្តិសង្ឆាទិសេសប៉ុណ្ណោះ
មិនមែនធ្វើដល់ភិក្ខុដែលត្រូវអាបត្តិបារាជិកទេ ។

កម្មក្ខន្ធកេ តជ្ជនីយកម្មំ អធម្មកម្មំ

[៧] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជ-
នីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ឧរ្ជ-
សន្តញ្ច អសម្មុខា កតំ ហោតិ អធម្មេន កតំ ហោតិ
វត្ថេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ ស-
មន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិន-
យកម្មញ្ច ឧរ្ជសន្តញ្ច ។

[៨] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ
តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច
ឧរ្ជសន្តញ្ច អប្បដិបុច្ឆា កតំ ហោតិ អធម្មេន កតំ
ហោតិ វត្ថេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តី-
ហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ
ហោតិ អវិនយកម្មញ្ច ឧរ្ជសន្តញ្ច ។

[៩] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជ-
នីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ឧរ្ជ-
សន្តញ្ច អប្បដិញ្ញាយ កតំ ហោតិ អធម្មេន កតំ ហោតិ

កម្មក្ខន្ធក: តជ្ជនីយកម្មជាកម្មដែលមិនត្រូវតាមធម៌

[៧] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[៨] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយការមិនសាកសួរ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្ម ផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ ៣ នេះឯង ។

[៩] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនតាមពាក្យប្តេជ្ញា ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១

វក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហាង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច ។

[១០] អបរេហិបិ ភិក្ខវេ តីហាង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច អជ្ឌាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហាង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច ។

[១១] អបរេហិបិ ភិក្ខវេ តីហាង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច អនេសនាតាមិនិយា អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វក្ខេន កតំ ហោតិ ឥមេ-ហិ ខោ ភិក្ខវេ តីហាង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរុបសន្តញ្ច ។

[១២] អបរេហិបិ ភិក្ខវេ តីហាង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច

កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្ម ផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ ៣ នេះឯង ។

[១០] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិន-យកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃ ទៀត គឺកម្មដែលធ្វើដោយមិនមានអាបត្តិ ១ កម្មដែលធ្វើមិនត្រូវតាម ធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជា អធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកប ដោយអង្គ ៣ នេះឯង ។

[១១] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិន-យកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃ ទៀត គឺកម្មដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី ១ កម្មដែលធ្វើមិន ត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយ-កម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ ផង ប្រកបដោយអង្គ ៣ នេះឯង ។

[១២] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិន-យកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃ

ជុរ្ជុបសន្ដញ្ចេ ឧសិតាយ អាបត្ដិយា កតំ ហោតិ អ-
ធម្មេន កតំ ហោតិ វត្ដេន កតំ ហោតិ ឥមេហិ ខោ
ភិក្ខវេ តីហង្គេហិ សមន្ដាគតំ ឥជ្ជនីយកម្មំ អធម្ម-
កម្មញ្ចេវ ហោតិ អវិនយកម្មញ្ចេ ជុរ្ជុបសន្ដញ្ចេ ។

[១៣] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្ដាគតំ
ឥជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ចេ
ជុរ្ជុបសន្ដញ្ចេ អចោទេត្វា កតំ ហោតិ អធម្មេន កតំ
ហោតិ វត្ដេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ
តីហង្គេហិ សមន្ដាគតំ ឥជ្ជនីយកម្មំ អធម្មកម្មញ្ចេវ
ហោតិ អវិនយកម្មញ្ចេ ជុរ្ជុបសន្ដញ្ចេ ។

[១៤] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្ដាគតំ
ឥជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ចេ
ជុរ្ជុបសន្ដញ្ចេ អសារេត្វា កតំ ហោតិ អធម្មេន កតំ
ហោតិ វត្ដេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ
តីហង្គេហិ សមន្ដាគតំ ឥជ្ជនីយកម្មំ អធម្មកម្មញ្ចេវ
ហោតិ អវិនយកម្មញ្ចេ ជុរ្ជុបសន្ដញ្ចេ ។

ទៀត គឺកម្មដែលធ្វើដោយទេសិតាបត្តិ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[១៣] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនបានចោទសិនហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជ-នីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអា-ក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[១៤] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិ-នយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនបានរំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនី-យកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអា-ក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[១៥] អបរេហិបិ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរូបសន្តញ្ច អាបត្តី អនាវេបេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វត្ថេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុរូបសន្តញ្ច ។

អធម្មកម្ម ទ្វាទសកំ និដ្ឋិតំ ។

[១៦] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ តជ្ជនីយ-កម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុរូបសន្តញ្ច សម្មុខា កតំ ហោតិ បដិបុច្ឆា កតំ ហោតិ បដិញ្ញា-យ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហាន្តេហិ ស-មន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយ-កម្មញ្ច សុរូបសន្តញ្ច ។

[១៧] អបរេហិបិ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុរូ-បសន្តញ្ច អាបត្តិយា កតំ ហោតិ ទេសនាគាមិនិយា

[១៥] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិ-
នយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃ
ទៀត គឺកម្មដែលមិនលើកអាបត្តិឡើងសិនហើយស្រាប់តែធ្វើ ១ កម្ម
ដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ
តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយ
អាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់ តជ្ជនីយកម្មមានចំនួន ១២ ក្នុងអធម្មកម្ម ។

[១៦] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាកម្មប្រកបដោយធម៌
ផង ជាកម្មប្រកបដោយវិនយផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកប
ដោយអង្គ ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ ១ កម្មដែលធ្វើដោយការ
សាកសួរ ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនី-
យកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង
ប្រកបដោយអង្គ ៣ នេះឯង ។

[១៧] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជា
វិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣
ដទៃទៀត គឺ កម្មដែលធ្វើតាមអាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិជា

អាបត្តិយា កតំ ហោតិ អនេសិតាយ អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុ-រូបសន្តញ្ច ។

[១៨] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុរូបសន្តញ្ច ចោទេត្វា កតំ ហោតិ សារេត្វា កតំ ហោតិ អាបត្តឺ អាវេបេត្វា[១] កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្ម-កម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុរូបសន្តញ្ច ។

[១៩] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុរូ-បសន្តញ្ច សម្មុខា កតំ ហោតិ ធម្មេន កតំ ហោតិ សមក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយ-កម្មញ្ច សុរូបសន្តញ្ច ។

---

១ ឱ. ណេបេត្វា ។

ទេសនាគាមិនី ១ កម្មដែលធ្វើដោយអទេសិតាបត្តិ ១ ម្នាលភិក្ខុទាំង-ឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[១៨] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិន-យកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលចោទហើយទើបធ្វើ ១ កម្មដែលរំលឹកហើយទើបធ្វើ ១ កម្ម ដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកប ដោយអង្គ ៣ នេះឯង ។

[១៩] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើចំពោះមុខ ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយការ ព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[២០] អបរេហិបិ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច បដិបុច្ឆា កតំ ហោតិ ឆម្នេ កតំ ហោតិ សមក្ខេ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

[២១] អបរេហិបិ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូ-បសន្តញ្ច បដិញ្ញាយ កតំ ហោតិ ឆម្នេ កតំ ហោតិ សមក្ខេ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយ-កម្មញ្ច សុវូបសន្តញ្ច ។

[២២] អបរេហិបិ ភិក្ខវេ តីហាន្តេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូ-បសន្តញ្ច អាបត្តិយា កតំ ហោតិ ឆម្នេ កតំ ហោតិ

[២០] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលសាកសួរហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្ម-កម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[២១] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្ម ផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[២២] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជា វិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើតាមអាបត្តិ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែល

សមក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយ-
កម្មញ្ច សុវូបសន្តញ្ច ។

[២៣] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូ-
បសន្តញ្ច ឧសជ្ជាតាមិនិយា អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្ម-
កម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

[២៤] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូ-
បសន្តញ្ច អនេសិតាយ អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

[២៥] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច

ធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្ម-
កម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ
អង្គ ៣ នេះឯង ។

[២៣] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយ-
កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ
កម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី ១ កម្មដែលធ្វើត្រូវតាមធម៌ ១
កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម
ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកប
ដោយអង្គ ៣ នេះឯង ។

[២៤] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយ-
កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត
គឺកម្មដែលធ្វើដោយអទេសិតាបត្តិ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែល
ធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្ម
ផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ
អង្គ ៣ នេះឯង ។

[២៥] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយ-
កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ

សុវ្ជបសន្ដញ្ចេ ចោទេត្វា កតំ ហោតិ ឆម្ទេន កតំ ហោតិ សមក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ឥជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវ្ជបសន្ដញ្ច ។

[២៦] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ឥជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវ្ជ-បសន្ដញ្ច សារេត្វា កតំ ហោតិ ឆម្ទេន កតំ ហោតិ សមក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ឥជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយ-កម្មញ្ច សុវ្ជបសន្ដញ្ច ។

[២៧] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ឥជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវ្ជ-បសន្ដញ្ច អាបត្តឺ អារោបេត្វា[1] កតំ ហោតិ ឆម្ទេន កតំ ហោតិ សមក្ខេន កតំ ហោតិ ឥមេហិ ខោ ភិក្ខ-វេ តីហង្គេហិ សមន្នាគតំ ឥជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវ្ជបសន្ដញ្ច ។

ធម្មកម្មេ ទ្វាទសកំ[2] និដ្ឋិតំ ។

---

១ ឱ. ពោបេត្វា ។ ២ ធម្មកម្មទ្វាទសកំ ។

កម្មដែលចោទហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[២៦] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[២៧] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិន-យកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់តជ្ជនីយកម្មមានចំនួន ១២ ក្នុងធម្មកម្ម ។

កម្មក្ខន្ធកេ តិណ្ណំ ភិក្ខូនំ តជ្ជនីយកម្មករណំ

[២៨] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុ-
ណោ អាគន្ត្វមាណោ សង្ឆោ តជ្ជនីយកម្មំ ការេយ្យ
ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ
ភស្សការកោ សង្ឆេ អធិករណការកោ ពាលោ
ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ តិហិសំ-
សង្ឆោ វិហរតិ អនជ្ជុលោមិកេហិ តិហិសំសត្ថេហិ ឥ-
មេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុណោ
អាគន្ត្វមាណោ សង្ឆោ តជ្ជនីយកម្មំ ការេយ្យ ។

[២៩] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស
ភិក្ខុណោ អាគន្ត្វមាណោ សង្ឆោ តជ្ជនីយកម្មំ ការេយ្យ
អធិសីលេ សីលវិបន្ណោ ហោតិ អជ្ឌាចារេ អាចារវិបន្ណោ
ហោតិ អតិទិដ្ឋិយា ទិដ្ឋិវិបន្ណោ ហោតិ ឥមេហិ ខោ
ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុណោ អាគន្ត្ង-
មាណោ សង្ឆោ តជ្ជនីយកម្មំ ការេយ្យ ។

[៣០] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស
ភិក្ខុណោ អាគន្ត្វមាណោ សង្ឆោ តជ្ជនីយកម្មំ ការេយ្យ
ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ

[២៨] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺភិក្ខុអ្នកបង្ក ហេតុ បង្ក ជម្លោះ បង្ក ទាស់ទែង បង្ក តិរច្ឆានកថា បង្ក អធិករណ៍ ក្នុងសង្ឆ ១ ភិក្ខុ ពាលមិនឆ្ងាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ ១ ភិក្ខុ នៅ ប្រទ្ឆ្ងក-ប្រទ្ឆំ ដោយ គ្រហស្ថ ដោយ ការ ប្រទ្ឆ្ងក ប្រទ្ឆំ មិនសមគួរ ១ ម្នាលភិក្ខុទាំង-ឡាយ កាលបើសង្ឆប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលប្រកប ដោយអង្គ ៣ នេះ ចុះ ។

[២៩] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយ-កម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុ មានសីលវិបត្តិ[១] ក្នុងអធិសីល ១ ភិក្ខុ មានអាចារ វិបត្តិ ក្នុងអជ្ឈាចារ ១ ភិក្ខុ មានទិដ្ឋិ វិបត្តិ ក្នុងអតិទិដ្ឋិ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយ-កម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះ ឯង ។

[៣០] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាថ្នា ក៏គប្បីធ្វើ តជ្ជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុ ពោល តិះដៀលព្រះពុទ្ធ ១ ភិក្ខុ ពោលតិះដៀលព្រះធម៌ ១ ភិក្ខុ ពោលតិះដៀល

---

១ ក្នុងទីឯទៀត លោកសំដៅយកអាបត្តិបារាជិកនិងសង្ឆាទិសេស ប៉ុន្តែក្នុងទីនេះសំដៅយក អាបត្តិសង្ឆាទិសេសតែម្យ៉ាង ហេតុនេះសង្ឆមិនត្រូវធ្វើតជ្ជនីយកម្មព្រោះត្រូវអាបត្តិបារាជិកទេ សង្ឆត្រូវធ្វើតជ្ជនីយកម្មបានចំពោះតែត្រូវអាបត្តិសង្ឆាទិសេសតែម្យ៉ាងប៉ុណ្ណោះ (សារត្ថទីបនី-ដីកា) ។

សជ្ជ្ សជ្ជ អវណ្ណ ភាសតិ ឥមេហិ ខោ ភិក្ខវេ តីហាត្តេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខ្ មានោ សង្ឆ្យ តជ្ជ-នីយកម្មំ ការេយ្យ ។

[៣១] តិណ្ណ ភិក្ខវេ ភិក្ខុនំ អាកង្ខ្ មានោ សង្ឆ្យ តជ្ជនីយកម្មំ ការេយ្យ ឯកោ ភណ្ឌនការកោ ។ បេ ។ សង្ឆ្យ អធិការណការកោ ឯកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ ឯកោ តិហិ-សំសង្ខ្ តិហាតិ អនុលោមិកេហិ តិហិសំសត្តេហិ ឥមេសំ ខោ ភិក្ខវេ តិណ្ណ ភិក្ខុនំ អាកង្ខ្ មានោ សង្ឆ្យ តជ្ជនីយកម្មំ ការេយ្យ ។

[៣២] អបរេសំបិ ភិក្ខវេ តិណ្ណ ភិក្ខុនំ អាកង្ខ្-មានោ សង្ឆ្យ តជ្ជនីយកម្មំ ការេយ្យ ឯកោ អធិសីលេ សីលវិបន្ន ហោតិ ឯកោ អជ្ឌ្ឌាចារេ អាចារវិបន្ន ហោតិ ឯកោ អតិទិដ្ឌិយ ទិដ្ឌិវិបន្ន ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណ ភិក្ខុនំ អាកង្ខ្ មានោ សង្ឆ្យ តជ្ជនីយកម្មំ ការេយ្យ ។

ព្រះសង្ឆ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាជ្ញ ក៏គប្បីធ្វើតជ្ជនី-
យកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

[៣១] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាជ្ញ ក៏គប្បីធ្វើតជ្ជ-
នីយកម្មដល់ភិក្ខុ ៣ ពួក គឺភិក្ខុមួយពួកជាអ្នកបង្កហេតុ ។ បេ ។ បង្ក
អធិករណ៍ក្នុងសង្ឆ ១ ភិក្ខុមួយពួកលួងមិនធ្ងាស មានអាបត្តិច្រើន
មិនមានការកំណត់អាបត្តិ ១ ភិក្ខុមួយពួកនៅប្រឡូកប្រឡំដោយគ្រ-
ហស្ថដោយការប្រឡូកប្រឡំមិនសមគួរ ១ ម្នាលភិក្ខុទាំងឡាយ កាលបើ
សង្ឆប្រាជ្ញ ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

[៣២] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាជ្ញ ក៏គប្បីធ្វើ
តជ្ជនីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុមួយពួកមានសីលវិបត្តិក្នុង
អធិសីល ១ ភិក្ខុមួយពួកមានអាចារវិបត្តិក្នុងអជ្ឈាចារ ១ ភិក្ខុមួយពួក
មានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាជ្ញ ក៏
គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

កម្មក្ខន្ធកេ តិណ្ណំ ភិក្ខូនំ តជ្ជនីយកម្មករណំ

[៣៣] អបរេសំបិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខ-
មានោ សង្ឆោ តជ្ជនីយកម្មំ ការេយ្យ ឯកោ ពុទ្ធស្ស
អវណ្ណោ ភាសតិ ឯកោ ធម្មស្ស អវណ្ណោ ភាសតិ ឯកោ
សង្ឆស្ស អវណ្ណោ ភាសតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ
ភិក្ខូនំ អាកង្ខមានោ សង្ឆោ តជ្ជនីយកម្មំ ការេយ្យ ។

អាកង្ខមានច្ឆក្កំ និដ្ឋិតំ ។

[៣៤] សង្ឆេន[១] តជ្ជនីយកម្មការេន ភិក្ខវេ
ភិក្ខុនា សម្មាវត្តិតព្វំ ។ ត្រាយំ សម្មាវត្តនា ន
ឧបសម្ប្បាទេតព្វំ ន និស្សយោ ទាតព្ពោ ន សាមណេរោ
ឧបដ្ឋាបេតព្ពោ ន ភិក្ខុនោវាទកសម្មតិ សាទិតព្ពា
សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្ពា យាយ អាបត្តិយា
សង្ឆេន តជ្ជនីយកម្មំ ការិតំ ហោតិ សា អាបត្តិ ន
អាបជ្ជិតព្ពា អញ្ញា វ តាទិសិកា តតោ វ ចាបិដ្ឋតរា
ការិតំ ន ការិតព្វំ ការិកា ន ការិតព្ពា ន បាត-
ត្ត ស្ស ភិក្ខុនោ ឧចោសថោ ឋបេតព្ពោ ន ឧបារណា

---

១ ឱ. សង្ឆេនាតិ ន ទិស្សតិ ។

កម្មក្ខន្ធក: ការធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួក

[៣៣] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាជ្ញា ក៏គប្បីធ្វើតជ្ជ-នីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុមួយពួក ពោលតិះដៀលព្រះ ពុទ្ធ ភិក្ខុមួយពួក ពោលតិះដៀលព្រះធម៌ ភិក្ខុមួយពួក ពោលតិះដៀលព្រះ សង្ឆ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឆប្រាជ្ញា ក៏គប្បីធ្វើតជ្ជនីយកម្ម ដល់ភិក្ខុ ៣ ពួកនេះឯង ។

ចប់ (តជ្ជនីយកម្ម) ដែលសង្ឆប្រាជ្ញានឹងធ្វើមានចំនួន ៦ ។

[៣៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឆធ្វើតជ្ជនីយកម្មហើយ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ ។ ការប្រព្រឹត្តវត្តដោយប្រពៃក្នុងតជ្ជនីយកម្ម នោះដូចេ្នះ គឺភិក្ខុ (ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយនោះ) មិនត្រូវឱ្យ ឧបសម្ប្ទា មិនត្រូវឱ្យនិស្សយ មិនត្រូវឱ្យសាមណេរបម្រើខ្លួន មិនត្រូវ ទទួលការសន្ទនខ្លួន ជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឆបានសន្ទនហើយ ក៏ គង់មិនត្រូវប្រដៅភិក្ខុនីដែរ សង្ឆបានធ្វើតជ្ជនីយកម្ម ព្រោះអាបត្តិណា កុំគប្បីឱ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃប្រហែលគ្នាក្តី ឬក៏អាបត្តិធ្ងន់ ជាងអាបត្តិមុននោះក្តី មិនត្រូវតិះដៀលតជ្ជនីយកម្ម មិនត្រូវតិះដៀលពួក ភិក្ខុអ្នកធ្វើតជ្ជនីយកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា

ឋបេតព្វា ន សវចនីយំ ការេតព្វំ ន អនុវាទោ ឋ-
ឋបេតព្វោ ន ឱការសោ ការេតព្វោ ន ចោទេតព្វោ ន
សារេតព្វោ ន ភិក្ខូ[1] ភិក្ខូហិ សម្ឆ្យោជេតព្វន្តិ ។

តជ្ជនីយកម្ម អដ្ឋារសវត្តំ និដ្ឋិតំ ។

[៣៤] អថ ខោ ឆ្លោ ឋណ្ណកលោហិតកានំ
ភិក្ខូនំ តជ្ជនីយកម្មំ អការិ ។ តេ ឆ្លេន តជ្ជ-
នីយកម្មកតា សម្ម្ យ វត្តន្តិ លោមំ ចាតេន្តិ ឧត្តារ
វត្តន្តិ ភិក្ខូ ឧបសង្ក្រមិត្វា ឯវំ វទេន្តិ ឆ ឆ ! ១ អាវុសោ
ឆ្លេ ! ១ តជ្ជនីយកម្មកតា ! ១ ! ១ ! ១

ដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) មិនត្រូវទទួលនាទីជាធំក្នុងវត្ត មិនត្រូវឱ្យធ្វើឱកាស[១] មិនត្រូវចោទគេ (ដោយវត្ថុ ឬ ដោយអាបត្តិ) មិនត្រូវរំលឹក (ទោសអ្នកដទៃ) មិនត្រូវ ប្រកបពួកភិក្ខុ (ឱ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ។

ចប់វត្ត ១៨ ក្នុងតជ្ជនីយកម្ម ។

[៣៥] លំដាប់នោះឯង សង្ឆបានធ្វើតជ្ជនីយកម្ម ដល់ពួកបណ្ដុកភិក្ខុ និងលោហិតកភិក្ខុ ។ ភិក្ខុទាំងឡាយនោះ ដែលសង្ឆបានធ្វើតជ្ជនីយ-កម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងមរោម[២] ប្រព្រឹត្តវត្តគួរដល់ កិរិយារលាស់ចេញចាកកម្ម រួចក៏ចូលទៅរកភិក្ខុទាំងឡាយ ហើយនិយាយ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ យើងខ្ញុំដែលសង្ឆបានធ្វើតជ្ជនី-យកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងមរោម ប្រព្រឹត្តវត្តគួរ ដល់កិរិយារលាស់ចេញចាកកម្មហើយ យើងខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត ។ ភិក្ខុទាំងឡាយយកសេចក្ដីនុ៎ះ ក្រាបបង្គំទូលព្រះមានព្រះភាគ ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឆចូរអម្ងាប់តជ្ជនីយកម្ម ដល់ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុចុះ ។

---

១ ភិក្ខុដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ មិនត្រូវសូមឱកាសនឹងភិក្ខុណាមួយដែលមាន ទោស ដើម្បីចោទភិក្ខុនោះ ។ ២ ស្លូតសុភាពរាបទាប ។

កម្មក្ខន្ធកេ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្ពំ

[៣៦] បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្ពំ ឧបសម្ប-ន្នេតិ និស្សយំ ទេតិ សាមណេរំ ឧបដ្ឋាបេតិ ភិក្ខុនោ-ឱវទកសម្មតឺ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្ពំ ។

[៣៧] អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នា-គតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្ពំ យាយ អាបត្តិយា សង្ឆេន តជ្ជនីយកម្មំ កតំ ហោតិ តំ អាបត្តឺ អាបជ្ជតិ អញ្ញ វ តាទិសិកំ តតោ វ ចាបិដ្ឋតរំ កម្មំ ករហតិ កម្មិកេ ករហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្ពំ ។

[៣៨] អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្ពំ បក-តត្តស្ស ភិក្ខុនោ ឧចោសថំ ឋបេតិ ឧបារណំ ឋបេតិ សវចនីយំ ការេតិ អនុវាទំ បដ្ឋបេតិ ឱកាសំ ការេតិ

កម្មក្ខន្ធក: តជ្ជនីយកម្មដែលសង្ឆមិនត្រូវរម្ងាប់

[៣៦] ម្នាលភិក្ខុទាំងឡាយ សង្ឆមិនត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុឱ្យឧបសម្បទា ១ ភិក្ខុឱ្យនិស្សយ ១ ភិក្ខុឱ្យសាមណេរបម្រើខ្លួន ១ ភិក្ខុទទួលការសន្ទនខ្លួនជាអ្នកប្រដៅភិក្ខុនី ១ ភិក្ខុដែលសង្ឆសន្ទនហើយប្រៀនប្រដៅភិក្ខុនីទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ សង្ឆមិនត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

[៣៧] ម្នាលភិក្ខុទាំងឡាយ សង្ឆមិនត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឆធ្វើតជ្ជនីយកម្ម ព្រោះអាបត្តិណាហើយត្រឡប់ត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រ-ហែលគ្នានឹងអាបត្តិមុននោះ ១ ឬក៏អាបត្តិធ្ងន់ជាងអាបត្តិមុននោះ ១ ភិក្ខុតិះដៀលតជ្ជនីយកម្ម ១ ភិក្ខុតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឆមិនត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះទេ ។

[៣៨] ម្នាលភិក្ខុទាំងឡាយ សង្ឆមិនត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុហាមឧបោសថរបស់ភិក្ខុជាបកតត្ត ១ ភិក្ខុហាមបវារណារបស់ភិក្ខុជាបកតត្ត ១ ភិក្ខុធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) ១ ភិក្ខុទទួលនាទីជាធំក្នុងវត្ត ១ ភិក្ខុដែលឱ្យធ្វើឱ្យកាស

ចោទេតិ សាវេតិ ភិក្ខូ ភិក្ខូហិ សម្ឆយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្ឋាគតស្ស ភិក្ខុនោ ឥជ្ជ-នីយកម្មំ ន បដិប្ឆស្ឆម្ភេតព្ពំ ។

នប្ឆដិប្ឆស្ឆម្ភេតព្ពអដ្ឋារសកំ និដ្ឋិតំ ។

[៣៩] បញ្ចហិ ភិក្ខវេ អង្គេហិ សមន្ឋាគតស្ស ភិក្ខុនោ ឥជ្ជនីយកម្មំ បដិប្ឆស្ឆម្ភេតព្ពំ ន ឧបសម្ឆា-ទេតិ ន និស្ឆយំ ទេតិ ន សាមណេរំ ឧបដ្ឋាបេតិ ន ភិក្ខុនោ ឱវទកសម្មតឺ សាទិយតិ សម្ម្ឍតោបិ ភិក្ខុនិយោ ន ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្ឋាគ-តស្ស ភិក្ខុនោ ឥជ្ជនីយកម្មំ បដិប្ឆស្ឆម្ភេតព្ពំ ។

[៤០] អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្ឋាគ-តស្ស ភិក្ខុនោ ឥជ្ជនីយកម្មំ បដិប្ឆស្ឆម្ភេតព្ពំ យាយ អាបត្តិយា សង្ឆេន ឥជ្ជនីយកម្មំ ឥតំ ហោតិ តំ អាបត្តឺ ន អាបជ្ជតិ អញ្ញ វ តាទិសិកំ ឥតោ វ ចា-បិជ្ជតរំ ឥកម្មំ ន ករហតិ ឥកម្ម្ឍកេ ន ករហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្ឋាគតស្ស ភិក្ខុនោ ឥជ្ជនីយកម្មំ បដិប្ឆស្ឆម្ភេតព្ពំ ។

(ដើម្បីចោទ) ១ ភិក្ខុចោទគេ ១ ភិក្ខុរំលឹកគេ ១ ភិក្ខុប្រកបពួកភិក្ខុ (ឱ្យ ឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឆមិនត្រូវរម្ងាប់ តជ្ជនីយកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះទេ ។

ចប់តជ្ជនីយកម្មដែលសង្ឆមិនត្រូវរម្ងាប់មានចំនួន ១៨ ។

[៣៩] ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុ ដែលប្រកបដោយអង្គ ៥ គឺភិក្ខុមិនឱ្យឧបសម្បទា ១ មិនឱ្យនិស្សយ ១ មិនឱ្យសាមណេរបម្រើខ្លួន ១ មិនទទួលការសន្ទនខ្លួនជាអ្នកប្រដៅភិក្ខុនី ១ បើទុកជាសង្ឆសន្ទនឱ្យហើយ ក៏គង់មិនទៅប្រដៅភិក្ខុនីទាំងឡាយ ១ ម្នាល ភិក្ខុទាំងឡាយ សង្ឆត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

[៤០] ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុ ដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឆធ្វើតជ្ជនីយកម្ម ព្រោះ អាបត្តិណាហើយ មិនត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលគ្នានឹង អាបត្តិមុននោះ ១ ឬក៏អាបត្តិធ្ងន់ជាងអាបត្តិមុននោះ ១ មិនតិះដៀលតជ្ជនីយ-កម្ម ១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

កម្មក្ខន្ធកេ តជ្ជនីយកម្មប្បដិប្បស្សទ្ធិ

[៤១] អជ្ជហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ បដិប្បស្សម្ភេតព្វំ ន បកតត្តស្ស ភិក្ខុនោ ឧចោសថំ ឋបេតិ ន ឋារណំ ឋបេតិ ន សវចនីយំ ការេតិ ន អនុវាទំ បដ្ឋបេតិ ន ឱកាសំ ការេតិ ន ចោទេតិ ន សារេតិ ន ភិក្ខូ ភិក្ខូហិ សម្ប-យោជេតិ ឥមេហិ ខោ ភិក្ខវេ អជ្ជហង្គេហិ សមន្នា-គតស្ស ភិក្ខុនោ តជ្ជនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។

[៤២] ឯវញ្ចេ បន ភិក្ខវេ បដិប្បស្សម្ភេតព្វំ ។ តេហិ ភិក្ខវេ បណ្ណ្ណាការលោហិតកេហិ ភិក្ខូហិ សង្ឆ្យ ឧបសង្ក្រមិត្វា ឯកំសំ ឧត្តរាសង្គំ ការិត្វា វុឌ្ឍានំ ភិក្ខូនំ ចាបេ ឋត្វិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឺ បគ្គហេត្វា ឯវមស្ស វចនីយោ មយំ ភន្តេ សង្ឆេន តជ្ជនីយកម្ម-ការ សម្ម ឋ្ឋាម លោមំ ចាតេម ឌេត្ថារ ឋ្ឋាម

កម្មក្ខន្ធក: ការរម្ងាប់តជ្ជនីយកម្ម

[៤១] ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុមិនហាមឧបោសថរបស់ភិក្ខុជាបកតត្ត ១ មិនហាមបវារណារបស់ភិក្ខុជាបកតត្ត ១ មិនធ្វើជាអ្នកមានមាត់ពាក្យ ១ មិនទទួលនាទីជាធំក្នុងវត្ត ១ មិនឱ្យធ្វើឱកាស (ដើម្បីចោទ) ១ មិនចោទគេ ១ មិនរំលឹកគេ ១ មិនប្រកបពួកភិក្ខុ (ឱ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវរម្ងាប់តជ្ជនីយកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះឯង ។

ចប់ តជ្ជនីយកម្មដែលសង្ឆត្រូវរម្ងាប់មានចំនួន ១៨ ។

[៤២] ម្នាលភិក្ខុទាំងឡាយ ឯតជ្ជនីយកម្មនោះ សង្ឆត្រូវរម្ងាប់យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ណុកភិក្ខុនិងលោហិតកភិក្ខុនោះគប្បីចូលទៅរកជំនុំសង្ឆ ហើយធ្វើសំពត់ឧត្តរាសង្គ:ធ្វៀងស្មាម្ខាងហើយសំពះបាទារបស់ភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយដែលសង្ឆធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងមរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម

តជ្ជនីយកម្មស្ស បដិប្បស្សទ្ធី យាចាមាតិ ។ ទុតិយម្បិ យាចិតញ្ញេវ ។ តតិយម្បិ យាចិតញ្ញា ។ ញ្យត្តេន ភិក្ខុនា បដិពលេន សង្ឆោ ញ្ញាបេតព្ពោ សុណាតុ មេ ភន្តេ សង្ឆោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ សង្ឆេន តជ្ជនីយកម្មកតា សម្មា វត្តន្តិ លោមំ ចាតេន្តិ ឧត្តានាំ វត្តន្តិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធី យាចន្តិ ។ យទិ សង្ឆស្ស បត្តកល្លំ សង្ឆោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ បដិប្បស្សម្ភេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឆោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ សង្ឆេន តជ្ជនីយកម្មកតា សម្មា វត្តន្តិ លោមំ ចាតេន្តិ ឧត្តានាំ វត្តន្តិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធី យាចន្តិ ។ សង្ឆោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយ-កម្មស្ស បដិប្បស្សទ្ធី សោ តុណ្ហស្ស យស្ស នក្ខ-មតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។

ខ្ញុំព្រះករុណាទាំងឡាយ មកសូមការរម្ងាប់តជ្ជនីយកម្ម ។ គប្បីសូមជាគម្រប់ពីរដងផង ។ គប្បីសូមជាគម្រប់បីដងផង ។ ភិក្ខុអ្នកឈ្វាសប្រតិពល គប្បីញ៉ាំងសង្ឆឱ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុនេះ ដែលសង្ឆធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម មកសូមការរម្ងាប់តជ្ជនីយកម្ម ។ បើកម្មមានកាលគួរដល់សង្ឆហើយ សង្ឆគប្បីរម្ងាប់តជ្ជនីយកម្ម របស់ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្តាប់ខ្ញុំ ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុនេះ ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងប-រោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម (ឥឡូវមក) សូមការរម្ងាប់តជ្ជនីយកម្ម ។ សង្ឆរម្ងាប់តជ្ជនីយកម្ម របស់ពួកបណ្ដុកភិក្ខុនិងលោហិតកភិក្ខុ ។ ការរម្ងាប់តជ្ជនីយកម្ម របស់ពួកបណ្ដុកភិក្ខុនិងលោ-ហិតកភិក្ខុ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្ដីនេះ ជាគម្រប់ពីរដងផង ។

សុណាតុ មេ ភន្តេ ។ បេ ។ យស្ស យស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស ប-ដិប្បស្សទ្ធិ សោ តុណ្ហីភាវ យស្ស ឧក្ខមតិ សោ ភា-សេយ្យ ។ តតិយម្ចិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឆោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ សង្ឆេន តជ្ជនីយកម្មកតា សម្មា វត្តន្តិ លោមំ ចាតេន្តិ ឧត្តានា វត្តន្តិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចន្តិ ។ សង្ឆោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ បដិប្ប-ស្សម្ភេតិ ។ យស្ស យស្មតោ ខមតិ បណ្ឌុកលោហិ-តកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហីភាវ យស្ស ឧក្ខមតិ សោ ភាសេយ្យ ។ បដិប្ប-ស្សទ្ធំ សង្ឆេន បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជ-នីយកម្មំ ខមតិ សជ្ជាយ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

តជ្ជនីយកម្មំ បឋមំ និដ្ឋិតំ ។

កម្មក្ខន្ធក: ការរម្ងាប់តជ្ជនីយកម្ម

បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្តាប់ខ្ញុំ ។ បេ ។ ក៏ការរម្ងាប់តជ្ជនីយ-កម្ម របស់ពួកបណ្ដុកកិក្ខុនិងលោហិតកកិក្ខុ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្ដីនេះ ជាគម្រប់បីដងផង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្តាប់ខ្ញុំ ពួកបណ្ដុកកិក្ខុនិងលោហិតកកិក្ខុនេះ ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងមភោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម (ឥទ្ធ្យវមក) សូមការរម្ងាប់តជ្ជនីយកម្ម ។ សង្ឆ ក៏រម្ងាប់តជ្ជនីយកម្ម របស់ពួកបណ្ដុកកិក្ខុនិងលោហិតកកិក្ខុ ។ ការរម្ងាប់តជ្ជនីយកម្ម របស់ពួកបណ្ដុកកិក្ខុនិងលោហិតកកិក្ខុ គួរដល់លោកមានអា-យុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។ សង្ឆបានរម្ងាប់តជ្ជនីយកម្ម របស់បណ្ដុកកិក្ខុនិងលោហិតកកិក្ខុហើយ (ការរម្ងាប់តជ្ជនីយកម្ម របស់ពួកបណ្ដុកកិក្ខុនិងលោហិតកកិក្ខុនេះ) គួរដល់សង្ឆ ព្រោះហេតុដូច្នោះ ទើបសង្ឆស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ចប់ តជ្ជនីយកម្មជាបឋម ។

[៤៣] តេន ខោ បន សមយេន អាយស្មា សេយ្យសកោ ពាលោ ហោតិ អព្យត្តោ[1] អាបត្តិពហុ-លោ អនបទានោ តិហិ សំ្ឆ ០ ០ ០

[៤៣] សម័យនោះឯង សេយ្យសកភិក្ខុមានអាយុ ជាភិក្ខុលូង់ មិនធ្ងាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ភិក្ខុទាំងឡាយជាបក-តត្តសោតក៏តែងឱ្យបរិវាស ឱ្យមូលាយបដិកស្សនៈ ឱ្យមានត្ត ឱ្យអញ្ជាន ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ហេតុអ្វី បានជាសេយ្យសកៈមានអាយុជាភិក្ខុលូង់ មិនធ្ងាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយ ជាបកតត្តសោត ក៏តែងឱ្យបរិវាស ឱ្យមូលាយបដិកស្សនៈ ឱ្យមានត្ត ឱ្យអញ្ជាន ។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។

[៤៤] ព្រោះនិទានេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ឱ្យប្រជុំភិក្ខុសង្ឆ ហើយទ្រង់ត្រាស់សួរភិក្ខុទាំងឡាយក្នុងកាលនោះថា ម្នាល

កម្មក្ខន្ធកេ និយស្សកម្មសេយ្យសកវត្ថុ

សចេ្ចកិរ ភិក្ខវេ សេយ្យសកោ ភិក្ខុ ពាលោ ហោតិ
អព្យត្តោ អាបត្តិពហុលោ អនបទានោ តិហិ សំ សេ ដ្ឋោ
វិហរតិ អនុ លោ មិ កេ ហិ តិ ហិ សំ សេ ក្ខ ហិ អ ប ិ ស្ស
ភិ ក្ខូ ប ក ត ត្តា ប រិ ាសំ ឧ ត្តា ម ូ លាយ ប ដិ ក ស្ស ត្តា
ម ាន ត្តំ ឧ ត្តា អ ព្ភ ត្តា ត ិ ។ ស ចេ្ច ភ ត ្ត ា ត ិ ។ ្ត ិ ត ្ត ហ ិ
ពុ ទ្ធ ោ ភ ត ្ត ា អ ន ុ ច ្ច ្ត ិ (១) ភ ិ ក ្ខ ុ ្ត (១) (១) (១)

ភិក្ខុទាំងឡាយ ឮថា សេយ្យសកភិក្ខុ ជាភិក្ខុលួងំ មិនឆ្ងាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយជាបកតត្តសោត ក៏តែងឱ្យបរិវាស ឱ្យមូលាយបដិកស្សន: ឱ្យមានត្ត ឱ្យអញ្ជាន ពិតមែនឬ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះសព្វញ្ញុពុទ្ធ ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសនោះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណ: មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុអ្វី បានជាមោយ-បុរសនោះ ជាបុគ្គលលួងំ មិនឆ្ងាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយជាបកតត្តសោត ក៏ឱ្យបរិវាស ឱ្យមូលាយបដិកស្សន: ឱ្យមានត្ត ឱ្យអញ្ជាន ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសនេះ មិនមែននាំឱ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ មិនមែនដឹកនាំពួកជនដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ លុះទ្រង់បន្ទោសរួច ទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឆចូរធ្វើនិយស្សកម្ម[1] ដល់សេយ្យសកភិក្ខុ

1 កម្មដែលសង្ឆត្រូវធ្វើឱ្យថយយស ។

តេ វត្តព្វន្តិ ។ ឯវញ្ហ បន ភិក្ខវេ ការេតព្ពំ ។ បឋមំ
សេយ្យសកោ ភិក្ខុ ចោទេតព្ពោ ចោទេត្វា សារេតព្ពោ
សារេត្វា អាបត្តិ អារោបេតព្ពា អាបត្តឺ អារោបេត្វា
ព្យត្តេន ភិក្ខុនា បដិពលេន សង្ឆោ ញាបេតព្ពោ
សុណាតុ មេ ភន្តេ សង្ឆោ អយំ សេយ្យសកោ
ភិក្ខុ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនប-
ទានោ តិហិសំសង្ហោ វិហរតិ អនុលោមិកេហិ តិហិ-
សំសក្តេហិ អបិស្ស ភិក្ខូ បកតត្តា បរិវាសំ ទេន្តា
មូលាយ បដិកស្សន្តា មានត្តំ ទេន្តា អព្ភេន្តា ។ យទិ
សង្ឆស្ស បត្តកល្លំ សង្ឆោ សេយ្យសកស្ស ភិក្ខុ-
នោ ឧិយស្សកម្មំ ការេយ្យ ឧិស្សាយ តេ វត្តព្វន្តិ ។
ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឆោ អយំ
សេយ្យសកោ ភិក្ខុ ពាលោ ហោតិ អព្យត្តោ អាបត្តិ-
ពហុលោ អនបទានោ តិហិសំសង្ហោ វិហរតិ អនុ-
លោមិកេហិ តិហិសំសក្តេហិ អបិស្ស ភិក្ខូ បក-
តត្តា បរិវាសំ ទេន្តា មូលាយ បដិកស្សន្តា មានត្តំ
ទេន្តា អព្ភេន្តា ។ សង្ឆោ សេយ្យសកស្ស ភិក្ខុនោ

